**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្ត សៀមរាប**

**ក្រុង សៀមរាប**

**សង្កាត់ ក្របីរៀល**

លេខ...៧០៥/១៥...ស.ក្រ

# សេចក្តីជូនដំណឹង

យើងខ្ញុំជាចៅសង្កាត់ និងសមាជិកក្រុមប្រឹក្សាសង្កាត់ក្របីរៀល សូមគោរពជម្រាបជូនបងប្អូនប្រជាពលរដ្ឋ ដែលរស់នៅសង្កាត់ក្របីរៀលទាំងមូល ឱ្យបានជ្រាបថាៈ យោងតាមស្មារតីប្រជុំពេញរបស់ក្រុមប្រឹក្សាសង្កាត់ក្របីរៀលកាលពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ បានឯកភាព និងអនុម័តដាក់ចេញនូវសេចក្តីជូនដំណឹងៈ(ការផ្សព្វផ្សាយគោលនយោបាយកាត់បន្ថយគ្រឿងស្រវឹង) នៅក្នុងសង្កាត់ក្របីរៀល ដូចនេះក្នុងនាមជាចៅសង្កាត់ក្របីរៀល យើងសូមជម្រាប និងជូនដំណឹងដូចតទៅ ៖

**ប្រការ១ ៖** ហាមលក់ ឬផឹកគ្រឿងស្រវឹងគ្រប់ប្រភេទនៅទីវត្តអារាម សាលារៀន មណ្ឌលសុខភាព សាលាសង្កាត់ចម្ងាយពី ៣០ ទៅ ៥០ម៉ែត្រ ។

**ប្រការ២ ៖** ហាមឪពុកម្តាយប្រើក្មេងក្រោមអាយុ១៧ឆ្នាំទិញ ឬផឹកស្រា ។

**ប្រការ៣ ៖** ហាមយកកំប៉ុងស្រាបៀរធ្វើជាកំប៉ុងជើងធូប ។

**ប្រការ៤ ៖** ហាមតម្រៀបកេសស្រាបៀរនៅមុខតូបលក់ ។

**ប្រការ៥ ៖** ហាមលើកផ្ទាំងប៉ាណូ ឬផ្ទាំងផ្សព្វផ្សាយគ្រឿងស្រវឹងគ្រប់ប្រភេទជិតវត្តអារាម សាលារៀន មណ្ឌលសុខភាព សាលាសង្កាត់ ។

**ប្រការ៦ ៖** ហាមផឹកគ្រឿងស្រវឹងរំខានដល់អ្នកដទៃនៅពេលយប់ ។

**ប្រការ៧ ៖** ហាមផឹកគ្រឿងស្រវឹងប្រើអំពើហិង្សាក្នុងគ្រួសារ និងអ្នកដទៃ ។

សេចក្តីជូនដំណឹងរបស់សង្កាត់ និងសមាជិកក្រុមប្រឹក្សាសង្កាត់ក្របីរៀលខាងលើនេះជាការជូនព័ត៌មានទៅដល់ប្រជាពលរដ្ឋទូទៅដែលរស់នៅក្នុងសង្កាត់ឱ្យបានជ្រាបថា ដើម្បីទប់ស្កាត់ និងកាត់បន្ថយការប្រើប្រាស់គ្រឿងស្រវឹងដែលជាបច្ច័យមិនល្អដល់ការអភិវឌ្ឍន៍មូលដ្ឋាន ការរំលោភសិទ្ធិមនុស្ស រសង្កាត់ក្របីរៀលទាំងមូល ។

សង្កាត់ក្របីរៀល,ថ្ងៃទី២៥...ខែកញ្ញា........ឆ្នាំ២០១៥

**ចៅសង្កាត់ក្របីរៀល**

**ឡឿម-ថៃ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត សៀមរាប

ក្រុង សៀមរាប

សង្កាត់ ក្របីរៀល

លេខ....៣៧៦/១៥

# សេចក្តីប្រកាស

## ស្តីពី:

## ការផ្សព្វផ្សាយគោលនយោបាយកាត់បន្ថយគ្រឿងស្រវឹង

យោងតាមស្មារតីនៃអង្គប្រជុំពេញរបស់ក្រុមប្រឹក្សាសង្កាត់ក្របីរៀលកាលពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ បានឯកភាព និងអនុម័តដាក់ចេញនូវសេចក្តីប្រកាសស្តីពី ការទប់ស្កាត់ និងកាត់បន្ថយការប្រើប្រាស់គ្រឿងស្រវឹងក្នុងសង្កាត់ទាំងមូល ដែលមានប្រការដូចខាងក្រោមនេះ

**ប្រការ១ ៖** ហាមលក់ ឬផឹកគ្រឿងស្រវឹងគ្រប់ប្រភេទនៅទីវត្តអារាម សាលារៀន មណ្ឌលសុខភាព សាលាសង្កាត់ចម្ងាយពី ៣០ ទៅ ៤០ម៉ែត្រ ។

**ប្រការ២ ៖** ហាមឪពុកម្តាយប្រើក្មេងក្រោមអាយុ១៧ឆ្នាំទិញស្រា ឬគ្រឿងស្រវឹងគ្រប់ប្រភេទ ។

**ប្រការ៣ ៖** ហាមយកកំប៉ុងស្រាបៀរធ្វើជាកំប៉ុងជើងធូប ។

**ប្រការ៤ ៖** ហាមតម្រៀបកេសស្រាបៀរនៅមុខតូបលក់ ។

**ប្រការ៥ ៖** ហាមលើកផ្ទាំងប៉ាណូ ឬផ្ទាំងផ្សព្វផ្សាយគ្រឿងស្រវឹងគ្រប់ប្រភេទជិតវត្តអារាម សាលារៀន មណ្ឌលសុខភាព និងសាលាសង្កាត់ ។

**ប្រការ៦ ៖** ហាមផឹកគ្រឿងស្រវឹងរំខានដល់អ្នកដទៃនៅពេលយប់ ។

**ប្រការ៧ ៖** ហាមផឹកគ្រឿងស្រវឹងប្រើអំពើហិង្សាក្នុងគ្រួសារ និងអ្នកដទៃ ។

យើងជាចៅសង្កាត់ និងសមាជិកក្រុមប្រឹក្សាសង្កាត់ក្របីរៀលបានចេញសេចក្តីប្រកាសនេះដែលមានប្រការដូចខាងលើដើម្បីទប់ស្កាត់ និងកាត់បន្ថយការប្រើប្រាស់គ្រឿងស្រវឹងក្នុងសង្កាត់ទាំងមូល និងមានសុពលភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

សូមអរគុណ!

សង្កាត់ក្របីរៀល ថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ២០១៥

ចៅសង្កាត់

ឡៀម ថៃ